# BRIEFING NOTES

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

២៨ មេសា ២០១៧

អ្នកនាំពាក្យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស៖ អ្នកស្រី អេលីសាបិត ត្រូស្សែល្ល (Elizabeth Throssell)

**ទីតាំង៖** ទីក្រុងហ្សឺណែវ

**កម្មវត្ថុ៖ (១) ការប្រហារជីវិតនៅរដ្ឋអារកាន់សាស់ (២) ប្រទេសកម្ពុជា**

**(១) ការប្រហារជីវិតនៅរដ្ឋអារកាន់សាស់**

………………. ………………. ………………. ………………. ………………. ………………. ……………….

**(២) ប្រទេសកម្ពុជា**

យើងសូមអំពាវនាវឲ្យអាជ្ញាធរកម្ពុជាដោះលែងដោយគ្មានការពន្យាពេលនូវអ្នកការពារសិទ្ធិមនុស្សចំនួនប្រាំរូប ដែលបាននិងកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្នរយៈពេលមួយឆ្នាំ ហើយដែលការឃុំខ្លួននេះ កាលពីម្សិលមិញ ត្រូវបានពន្យាពេលប្រាំមួយខែបន្ថែមទៀត ដោយចៅក្រមស៊ើបសួរ។ យើងសោកស្តាយថា ទោះបីជាមានមតិយោបល់ដោយក្រុមការងារអង្គការសហប្រជាជាតិទទួលបន្ទុកការឃុំខ្លួនដោយបំពាន ដែលចេញកាលពីខែវិច្ឆិកាបានសម្រេចថា ការឃុំខ្លួនបុគ្គលទាំងប្រាំរូបនេះគឺធ្វើឡើងដោយបំពានក្តី ក៏ការឃុំខ្លួនរបស់ពួកគាត់ ត្រូវបានពន្យាពេលបន្ថែមទៀត។

អ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបនេះ រួមមានបុគ្គលិកបួនរូបបម្រើការនៅអង្គការការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) មានឈ្មោះ លឹម មុនី នី វណ្ណដា នី សុខា និង យី សុខសាន្ត ព្រមទាំងអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជាអតីតបុគ្គលិកអង្គការអាដហុក គឺ លោក នី ចរិយា។ ពួកគេប្រឈមការចោទប្រកាន់ពីបទអំពើពុករលួយ ទាក់ទងនឹងជំនួយដែលពួកគេបានផ្តល់ទៅឲ្យស្ត្រីម្នាក់ដែលត្រូវគេអះអាងថាប្រឈមមុខនឹងការគាបសង្កត់ពីអាជ្ញាធរឲ្យផ្តល់សក្ខីកម្មក្លែងក្លាយ។ ស្ត្រីរូបនោះ ដែលពេលក្រោយមកបានទទួលស្គាល់ថាមានការគាបសង្កត់ពីអាជ្ញាធរឲ្យផ្តល់សក្ខីកម្មក្លែងក្លាយមែន។ នាងបានផ្តល់សក្ខីកម្មដែលគេកំពុងស្វែងរក ហើយបានអះអាងថា "បុគ្គលិកអាដហុកទាំង ៥ នាក់" បានសូកប៉ាន់គាត់ឲ្យនិយាយកុហកអ្នកស៊ើបអង្កេត។

ក្រុមការងារអង្គការសហប្រជាជាតិបានធ្វើសេចក្តីសន្និដ្ឋានក្នុងខែវិច្ឆិកា "ថាបុគ្គលទាំងប្រាំរូបនេះ ត្រូវបានឃុំខ្លួនដោយសារតែការអនុវត្តសិទ្ធិ និងសេរីភាពរបស់ខ្លួន" ហើយបានអំពាវនាវឲ្យមានការដោះលែងពួកគេ។ អ្នកជំនាញឯករាជ្យមួយចំនួនរបស់អ.ស.ប បានជំរុញផងដែរឲ្យដោះលែងពួកគេ ដោយពួកគាត់បានសម្តែងការខកចិត្តអំពីការប្រើប្រាស់ចំនាត់ការព្រហ្មទណ្ឌ "ជាលេសមួយដើម្បីបង្ក្រាប និងរារាំងការអនុវត្តស្របច្បាប់នូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងដើម្បីបំបិទមាត់អ្នកការពារសិទ្ធិមនុស្ស។"

ទោះបីជាយើងទទួលស្គាល់កាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ ដែលធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់លើករណីនេះក្តី ក៏ការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្ន គួរជាករណីអញ្ញត្រកម្ម ជាជាងច្បាប់ និងគួរត្រូវបានអនុញ្ញាតតែសម្រាប់ពេលដ៏ខ្លីបំផុតចាំបាច់ដែលអាចធ្វើបាន ផ្អែកលើភស្តុតាងច្បាស់លាស់ និងហេតុផលសុពលតាមផ្លូវច្បាប់ប៉ុណ្ណោះ។ យើងសោកស្តាយដែលកិច្ចធានាការពារនេះ ទំនងជាមិនត្រូវបានអនុវត្តតាមនៅក្នុងសវនាការសុំនៅក្រៅឃុំ។

ចប់

*សម្រាប់ព័ត៌មានបន្ថែម និង**សំណើព័ត៌មាន** សូមទាក់ទងមក លីហ្ស ត្រូស្សែល្ល (Liz Throssell) តាមរយៈ ទូស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៤៦៦ / ethrossell@ohchr.org) ឬ រ៉ាវីណា សេមដាសានី (Ravina Shamdasani) តាមរយៈទូស័ព្ទលេខ  (+៤១ ២២ ៩១៧  ៩១៦៩ / rshamdasani@ohchr.org) ឬ លោក រ៉ូភឺត ខូវីល្លេ (Rupert Colville) តាមរយៈទូស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧ ៦៧ / rcolville@ohchr.org)*

ចែក និងចែករំលែក - ទ្វីតធ៏៖ **@UNHumanRights** និងហ្វេសប៊ុក៖ **unitednationshumanrights**